# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧០០/១២៥

### ស្តីពី លក្ខន្តិកៈដោយឡែក

### នៃគ្រប់ខ័ណ្ឌគ្រាក់ខាររដ្ឋបាលក្រសួងមហាផ្ទៃ

***

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ [illegible]/១២[illegible] ចុះថ្ងៃ[illegible]១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំអង្គការសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០

### ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចបានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

មន្ត្រីរាជការនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ៣ .-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិមុខងារសាមញ្ញ នៅក្នុងអង្គភាពរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង ។

### ជំពូកទី ២
### ឋានន្តរស័ក្តិ នៃក្របខ័ណ្ឌ

**មាត្រា ៤ .-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃមាន ៣ ឋានន្តរស័ក្តិ :

| | | | | |
|---|---|---|---|---|
| -នាយភ្នាក់ងាររដ្ឋបាល | : | មាន | ០៦ | ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាលដើមខ្សែ | : | មាន | ១០ | ថ្នាក់ |
| -ភ្នាក់ងាររដ្ឋបាល | : | មាន | ១៥ | ថ្នាក់ ។ |

### ជំពូកទី ៣
### ការជ្រើសរើស

**មាត្រា ៥ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងដែលរៀបចំឡើង ដោយក្រសួងមហាផ្ទៃ ។ ចំនួននៃតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៦ .-**

ការប្រឡងប្រជែងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំ ឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៤
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧ .-**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមមាត្រា ១៦ និងមាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោល ។ ករណីខាងលើទាំងនេះ នេះត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ០៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិមួយរួចហើយ មន្ត្រីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរសក្តិ

**មាត្រា ៩ .-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

-គោរពវិន័យការងារបានត្រឹមត្រូវ

-សំរេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ភាគ៤ តាមវេនជ្រើសរើស និង ១ភាគ៤ តាមវេនអតីតភាព ។

មាត្រា ១០ .‒

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនកំណែងដែលទំនេរ នៅក្នុងឋានន្តរសក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋាននរសក្តិ ឬ តាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ :

-ឋានន្តរសក្តិនាយក្នាក់ងាររដ្ឋបាល = ៥ ភាគរយ

-ឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផៃ ។

មាត្រា ១១ .‒

អាចតម្លើងទៅក្នុងឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិភ្នាក់ងាររដ្ឋបាល ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយណា ដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ ។

មាត្រា ១២ .‒

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតម្លៃងកត្តា នៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៣ .‒

មន្ត្រី នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវដាក់អោយចូលនិវត្តន៍ នៅពេលដល់អាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

មាត្រា ១៤ ._

ចំនួនរៀបចំដំបូងនៃក្របខ័ណ្ឌថ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវកសាងចេញពីសមាហរណកម្ម នៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដ របស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល របស់ក្រសួងមហាផ្ទៃ និងតាមខេត្ត ក្រុង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ១៥ ._

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦ ._

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ១៧ ._

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ហត្ថលេខា

**ស ខេង យូ ហុកគ្រី**

★★★